ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ............................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា
## នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២

**សូមគោរព :**

- **គណៈអធិបតី**
- **លោក Arnaud de VILLEPOIX ជំនាញការ IMF ប្រចាំនៅធនាគារជាតិនៃកម្ពុជា**
- **លោក Robert Beerens ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Lachlan Fleming ជំនាញការនៅធនាគារជាតិនៃកម្ពុជា**
- **លោក Ye-Hong Ahn ជំនាញការធនាគារកណ្តាលកូរ៉េ នៅធនាគារជាតិនៃកម្ពុជា**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ជាមួយលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ ធនាគារជាតិនៃកម្ពុជាយើងតែងតែរៀបចំប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយ និងអបអរសាទរចំពោះលទ្ធផលការងាររបស់ខ្លួនដែលសម្រេចបាន និងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើងទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នាទាំងផ្នែកការងារនិងទំនាក់ទំនងសង្គមឱ្យកាន់តែជិតស្និទ្ធថែមទៀត ។ សន្និបាតយើងថ្ងៃនេះត្រូវបានរៀបចំឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៣ កាលពីដើមខែមិថុនាកន្លងមក ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំង ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ កសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយមានសុវត្ថិភាព និងមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា នៅឆមាសទី១ ឆ្នាំ២០១២ ដូចតទៅ ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

តាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆមាសទី១ ឆ្នាំ២០១២នេះ ស្ថានភាពសេដ្ឋកិច្ចពិភពលោកមានស្ថិរភាពជាបង្គួរ ដោយសារការងើបឡើងវិញបន្តិចម្តងៗនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ការខិតខំដោះស្រាយវិបត្តិបំណុលសាធារណៈនៅតំបន់ប្រាក់អឺរ៉ូ ការថយចុះនៃសម្ពាធអតិផរណា និងការស្តារឡើងវិញកាន់តែប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសកល បន្ទាប់ពីអាជ្ញាធរបានចាត់វិធានការដោះស្រាយវិបត្តិកន្លងមក ។

ស្ថានភាពសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០១២នេះ នឹងមានកំណើន ៣,៥% ធៀបនឹង ៣,៩% នៅឆ្នាំ២០១១ ។ ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍អឺរ៉ុបអាចមាននិន្នាការធ្លាក់ចុះក្នុងកម្រិតមួយទាប ខណៈដែលប្រទេសជឿនលឿនមួយចំនួននៅក្រៅតំបន់អឺរ៉ុប រួមទាំងប្រទេសជប៉ុនផងកំពុងប្រឈមនឹងកំណើនទាបនៅឡើយ ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើន ២,១% ធៀបនឹងកំណើន ១,៧% នាឆ្នាំ២០១១ ។ ចំពោះប្រទេសឧស្សាហកម្មនៅអាស៊ី អាចនឹងមានកំណើន ២,២% គឺខ្ពស់ជាងកម្រិត -0,២% នៅឆ្នាំ២០១១ ក្នុងនោះប្រទេសអូស្ត្រាលីមានកំណើន ៣% ធៀបនឹង ២% ឆ្នាំ២០១១ និងជប៉ុនមានកំណើន ២% ធៀបនឹង -0,៧% ឆ្នាំ២០១១ ។

ចំណែកឯប្រទេសកំពុងអភិវឌ្ឍន៍និងកំពុងងើបឡើងមានកំណើន ៥,៧% ធៀបនឹង ៦,២% ឆ្នាំ២០១១ ក្នុងនោះសេដ្ឋកិច្ចប្រទេសចិនត្រូវបានរំពឹងថានឹងមានកំណើន ៨,២% ធៀបនឹង ៩,២% នាឆ្នាំ២០១១ ។ ទន្ទឹមនោះ ប្រទេសកូរ៉េនិងតៃវ៉ាន់ដែលជាដៃគូពាណិជ្ជកម្មនិងវិនិយោគសំខាន់សម្រាប់កម្ពុជា ត្រូវបានរំពឹងថាមានកំណើន ៣,៥% និង ៣,៦% រៀងគ្នា ។ សេដ្ឋកិច្ចអាស៊ាននឹងមានកំណើន ៥,២% ធៀបនឹង ៤,៦% នៅឆ្នាំ២០១១ ។ ភាពល្អប្រសើរនេះ ដោយសារតំបន់អាស៊ីមានមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ និងបានអនុវត្តគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុទន់ភ្លន់ ដែលជារនាំងទប់ស្កាត់ការឆ្លងរាលដាលនៃវិបត្តិទីផ្សារហិរញ្ញវត្ថុ ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ បានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ តាមការព្យាករណ៍របស់រាជរដ្ឋាភិបាលរំពឹងថា នៅឆ្នាំ២០១២នេះ កំណើនសេដ្ឋកិច្ចនឹងកើនឡើងប្រមាណ ៧% ធៀបនឹង ៧,១% នៅឆ្នាំ២០១១ ។ កំណើននេះគាំទ្រដោយវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងការអនុវត្តគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើពិពិធកម្មវិស័យផលិតកម្ម ជាពិសេសវិស័យកសិកម្ម និងពិពិធកម្មទីផ្សារនាំចេញផង ពិតជាបានរួមចំណែកគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

## II/- លទ្ធផលការងារសំខាន់ៗដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួន ក្នុងការរក្សាស្ថិរភាពថ្លៃប្រកបដោយប្រសិទ្ធភាព ដោយរក្សាបាននូវស្ថិរភាពនៃតម្លៃប្រាក់រៀល និងអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក និងគ្រប់គ្រងអត្រាអតិផរណាឱ្យមានកម្រិតទាប ប្រែប្រួលក្នុងកម្រិតមួយអាចគ្រប់គ្រងបាន ។ តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរ សម្រាប់គាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។

សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗ ដូចខាងក្រោម ៖

នៅក្នុងឆមាសទី១ ឆ្នាំ២០១២នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃប្រមាណ ០,២% ធៀបនឹងខែមិថុនា នៅឆ្នាំ២០១១ ។ អត្រាអតិផរណាមាននិន្នាការថយចុះគួរឱ្យកត់សម្គាល់ ពី ៥,៨% នៅខែមករា មក ៣,១% នៅខែមិថុនា ។ រូបិយវត្ថុទូទៅ (M2) មានកំណើនឆ្នាំលើឆ្នាំ ១៣,៤% ដោយភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុមានកម្រិតប្រមាណ ៤៧% នៅខែមិថុនា ឆ្នាំ២០១២ ធៀបនឹង ៤២% នាគ្រាដូចគ្នានៅឆ្នាំមុន ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ ៣.៣០៣ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានចំនួនប្រមាណ ៤,៥ខែ ។ ការគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន ស្របតាមភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរ ដូចខាងក្រោម ៖

**១/- វិស័យធនាគារ** : វិស័យនេះមានការអភិវឌ្ឍនិងរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ និងបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាពនាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជមានចំនួន៣២ ធនាគារឯកទេសចំនួន៧ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣២ ក្នុងនោះមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧ ត្រូវបានអនុញ្ញាតឱ្យទទួលប្រាក់បញ្ញើពីសាធារណជន ប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជីចំនួន៣០ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន១ តតិយភាគីចំនួន១១ ការិយាល័យព័ត៌មានឥណទានចំនួន១ និងអាជីវកម្មប្តូរប្រាក់ដែលមានអាជ្ញាបណ្ណចំនួន ៤៧ និងបានចុះបញ្ជីចំនួន ១.៥១២ ។